Article
24

# បច្ចេកវិទ្យា និងភាពជាអ្នកដឹកនាំឌីជីថលនៅកម្ពុជា

បច្ចុប្បន្ននេះ ការប្រើប្រាស់បច្ចេកវិទ្យាត្រូវបានមើលឃើញថាមានភាពរីកចម្រើនយ៉ាងខ្លាំង ដោយការចាប់យកបច្ចេកវិទ្យាត្រូវបានចាត់ទុកថាជាភាពចាំបាច់ ទាំងសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ការបំពេញការងារ និងជាពិសេសសម្រាប់ការធ្វើអាជីវកម្ម ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ដល់ "**ភាពជាអ្នកដឹកនាំឌីជីថល**"។ ដោយឡែក នារយៈកាលចុងក្រោយ វិបត្តិជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់ការចាប់យកភាពជាអ្នកដឹកនាំឌីជីថល ដោយបានបង្កឱ្យមានការផ្លាស់ប្តូរនូវរបៀបរបបក្នុងការបំពេញការងារ និងការធ្វើអាជីវកម្មក្នុងបរិបទថ្មី។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសំខាន់ៗ អាចឱ្យអ្នកដឹកនាំឌីជីថលត្រៀមខ្លួនក្នុងការចាប់យកឱកាស ក៏ដូចជាទាញយកផលប្រយោជន៍សម្រាប់អាជីវកម្មតាមរយៈការឆ្លើយតបទៅនឹងនិន្នាការវិវត្តន៍នៃសង្គម សេដ្ឋកិច្ច។ តាមការសិក្សាបានបង្ហាញថាភាពជាអ្នកដឹកនាំឌីជីថលពិតជាមានសារៈសំខាន់សម្រាប់អាជីវកម្មក្នុងការចាប់យកការប្រើប្រាស់បច្ចេកវិទ្យាជាជំនួយក្នុងការបំពេញការងារ នៅក្នុងស្ថាប័ន និងអាជីវកម្ម ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងក្នុងការទំនាក់ទំនង បង្កើនលទ្ធភាពក្នុងការបំពេញការងារ និងជាពិសេស ធានានូវនិរន្តរភាពនៃអាជីវកម្មនៅក្នុងយុគសម័យឌីជីថល។

ភាពជាអ្នកដឹកនាំ គឺជាសមត្ថភាពរបស់បុគ្គលម្នាក់ ដែលមានឥទ្ធិពលក្នុងការដឹកនាំគ្រប់កាលៈទេសៈទាំងក្នុងស្ថាប័នរដ្ឋ និងឯកជន។ បន្ថែមពីនេះ ភាពជាអ្នកដឹកនាំត្រូវមានភាពច្បាស់លាស់, មានការសម្រេចចិត្តប្រកបដោយហេតុផល និងមានចក្ខុវិស័យវែងឆ្ងាយ ដើម្បីសម្រេចបាននូវគោលដៅរួម។ ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពមានចរិតលក្ខណៈ ដូចជា មានទំនុកចិត្តលើខ្លួនឯង, មានជំនាញទំនាក់ទំនង, មានគំនិតប្រកបដោយភាពច្នៃប្រឌិត, មានឆន្ទៈក្នុងការដោះស្រាយបញ្ហា និងអាចទទួលយកភាពផ្លាស់ប្តូរ។ យ៉ាងណាមិញ ក្នុងយុគសម័យឌីជីថល ភាពជាអ្នកដឹកនាំតាមបែបប្រពៃណីលែងមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការដឹកនាំប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលទៀតហើយ ដែលតម្រូវឱ្យមានការគិតគូរបន្ថែមពី "**ភាពជាអ្នកដឹកនាំឌីជីថល**"។ "**ភាពជាអ្នកដឹកនាំឌីជីថល**" ផ្តោតសំខាន់លើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការឆ្ពោះទៅរកឌីជីថលូបនីយកម្ម ដើម្បីរក្សាបាននូវភាពប្រកួតប្រជែងនៅលើទីផ្សារ ក៏ដូចជាការឆ្លើយតបបានយ៉ាងរហ័សទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យា។ ការផ្លាស់ប្តូរស្ថាប័ន ឱ្យមានភាពសមស្របសម្រាប់យុគសម័យឌីជីថល តាមរយៈដំណើរការនៃការកសាងសមត្ថភាពរបស់បុគ្គលិក ការកែលម្អរចនាសម្ព័ន្ធការងារ និងរបៀបរបបនៃការធ្វើការ គឺចាំបាច់ត្រូវឱ្យមានភាពជាអ្នកដឹកនាំឌីជីថល។ ភាពជាអ្នកដឹកនាំឌីជីថលដើតួរយ៉ាងសំខាន់ក្នុងការដឹកនាំ ក៏ដូចជា

ការគ្រប់គ្រងនូវលំហូរការងារ និងដំណើរការអាជីវកម្មឱ្យមានភាពរលូន តាមរយៈការចាប់យកបច្ចេកវិទ្យាថ្មីៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន និងការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា។ ភាពជាអ្នកដឹកនាំឌីជីថល ពិតជាមានភាពចាំបាច់ ដើម្បីធ្វើការផ្លាស់ប្តូរស្ថាប័ន ឱ្យមានភាពសមស្របសម្រាប់យុគសម័យឌីជីថល តាមរយៈដំណើរការនៃការកសាងសមត្ថភាពរបស់បុគ្គលិក ការកែលម្អរចនាសម្ព័ន្ធការងារ និងរបៀបរបបនៃការធ្វើការ។ បន្ថែមពីនេះទៀត វាមានតួនាទីសំខាន់ក្នុងការដឹកនាំស្ថាប័ន ក៏ដូចជាការគ្រប់គ្រងនូវលំហូរការងារ និងដំណើរការអាជីវកម្មឱ្យមានភាពរលូន តាមរយៈការចាប់យកបច្ចេកវិទ្យាថ្មីៗ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន និងការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា។

ខាងក្រោមនេះជាភាពខុសគ្នារវាងភាពជាអ្នកដឹកនាំបែបប្រពៃណី និងភាពជាអ្នកដឹកនាំឌីជីថល៖

**ចក្ខុវិស័យ៖** ចក្ខុវិស័យនៃភាពជាអ្នកដឹកនាំ គឺជាសមត្ថភាពក្នុងការផ្តោតអារម្មណ៍លើទិដ្ឋភាពសំខាន់របស់ការងារ ឬអាជីវកម្មខ្លួន ក៏ដូចជាអ្វីដែលអ្នកចង់សម្រេចបាន និងប្រភេទអ្នកដឹកនាំដែលអ្នកប្រាថ្នាចង់អនុវត្ត។ តាមរយៈចក្ខុវិស័យច្បាស់លាស់ អ្នកដឹកនាំអាចបង្កើតជាឥទ្ធិពលដែល ជួយជំរុញការអនុវត្តការងាររបស់បុគ្គលិក ព្រមទាំងអាចជួយទាក់ទាញមនុស្សជុំវិញខ្លួនឱ្យដើរតាមទិសដៅ និងក្តីស្រមៃរួម។ ចំពោះភាពជាអ្នកដឹកនាំឌីជីថល ចក្ខុវិស័យកើតចេញពីការយល់ដឹងផ្នែកអក្ខរកម្មឌីជីថល ចំណេះដឹងផ្នែកបច្ចេកទេសគ្រប់គ្រាន់ និងសមត្ថភាពក្នុងការអង្កេតតាមដានឱ្យបានហ្មត់ចត់លើចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុនខ្លួន។ លើសពីនេះទៀត អ្នកដឹកនាំឌីជីថល គឺជាបុគ្គលដែលជំរុញបរិវត្តកម្មឌីជីថល តាមរយៈការដាក់ចេញនូវគំនិតផ្តួចផ្តើមថ្មីៗ, យុទ្ធសាស្ត្រប្រទាក់ក្រឡាគ្នា, និងកម្មវិធីការងារច្បាស់លាស់។

**ភាពច្នៃប្រឌិត៖** អ្នកដឹកនាំដែលមានគំនិតច្នៃប្រឌិត មិនត្រឹមតែជាបុគ្គលដែលអាចបំផុសគំនិតច្រើននោះទេ ប៉ុន្តែគឺអាចផ្តល់សេរីភាពដល់អ្នកដទៃក្នុងការអភិវឌ្ឍគំនិតរបស់ពួកគេ និងតែងតែបើកចំហរទទួលយកគំនិតថ្មីៗ ដើម្បីពិភាក្សា។ យើងសង្កេតឃើញថា មនុស្សភាគច្រើនមានគំនិតដ៏អស្ចារ្យប៉ុន្តែខ្វះឆន្ទៈ, ការតាំងចិត្ត, និងភ័យខ្លាចក្នុងការធ្វើសកម្មភាព ដែលជាហេតុធ្វើឱ្យពួកគេមិនអាចក្លាយជាអ្នកដឹកនាំដ៏ជោគជ័យ។ ក្នុងន័យនេះ ភាពជាអ្នកដឹកនាំឌីជីថល ទាមទារចាំបាច់នូវភាពច្នៃប្រឌិត ដែលផ្តោតលើការទាញយកអត្ថប្រយោជន៍ពីការរីកចម្រើននៃបច្ចេកវិទ្យា និងសមត្ថភាពក្នុងការច្នៃបង្កើតថ្មីដោយត្រូវតាមដានជាប់ជាប្រចាំនូវការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា និងបរិបទសង្គម សេដ្ឋកិច្ច ដើម្បីអាចត្រួសត្រាយផ្លូវឈានទៅសម្រេចជោគជ័យ ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

**បណ្តាញទំនាក់ទំនង៖** សម្រាប់ភាពជាអ្នកដឹកនាំ បណ្តាញទំនាក់ទំនងគឺជាធាតុផ្សំដែលមិនអាចខ្វះបាន ដើម្បីពង្រឹងសម្ព័ន្ធភាពការងារ ឈានទៅសម្រេចគោលដៅរបស់ស្ថាប័ន។ ឈរលើស្មារតីនេះ អ្នកដឹកនាំឌីជីថលគួរមានជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីផ្សារភ្ជាប់បណ្តាញទំនាក់ទំនងជាយុទ្ធសាស្ត្រ សម្រាប់ក្រុមហ៊ុនក្នុងការប្រាស្រ័យទាក់ទង ផ្សព្វផ្សាយព័ត៌មាន ផលិតផល និងសេវាកម្មទៅកាន់មហាជន។ លើសពីនេះទៀត ការចូលរួមសិក្ខាសាលា និងកិច្ចប្រជុំនានា ក៏អាចឱ្យអ្នកដឹកនាំ

ឌីជីថលចាប់យកគំនិតថ្មីៗពីវេទិកាទាំងនោះ មកបម្រើជាផលប្រយោជន៍សម្រាប់អាជីវកម្មផងដែរ។

## I. សារៈសំខាន់ និងអត្ថប្រយោជន៍នៃភាពជាអ្នកដឹកនាំឌីជីថល

នាពេលបច្ចុប្បន្ន ភាពជាអ្នកដឹកនាំឌីជីថលជាកត្តាកំណត់ដ៏សំខាន់មួយ សម្រាប់ភាពជោគជ័យនៃអាជីវកម្ម។ ការកើនឡើងនូវចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គមបានផ្លាស់ប្តូរនូវការធ្វើទីផ្សាររបស់អាជីវកម្ម ការផ្សារភ្ជាប់ទំនាក់ទំនងជាមួយអតិថិជន និងដំណើរការអាជីវកម្មស្ទើរតែទាំងស្រុង។ ស្ថាប័ន និងអាជីវកម្មត្រូវការអ្នកដឹកនាំឌីជីថលសម្រាប់ដំណើរការប្រតិបត្តិការឌីជីថលក្នុងស្ថាប័នរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងឌីជីថលូបនីយកម្ម ក៏ដូចជាបញ្ហាប្រឈមដែលអាជីវកម្មកំពុងជួបប្រទះ ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

ខាងក្រោមនេះគឺជាសារៈសំខាន់នៃភាពជាអ្នកដឹកនាំឌីជីថល៖

**ការឆ្លើយតបនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល៖** ភាពជាអ្នកដឹកនាំឌីជីថលមានសារៈសំខាន់ ដោយអាចជួយស្ថាប័នមួយក្នុងការឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល, ជួយសម្រួលដល់លំហូរការងារ និងដំណើរការអាជីវកម្មរបស់ពួកគេ ដែលទាមទារឱ្យស្ថាប័នធ្វើការចាប់យកបច្ចេកវិទ្យាថ្មីៗ និងធានាឱ្យបានក្នុងការផ្តល់សេវាកម្មឌីជីថលជូនអតិថិជន។ ទន្ទឹមនេះ អ្នកដឹកនាំឌីជីថលក៏ដើរតួនាទីសំខាន់ក្នុងការនាំមកនូវភាពច្នៃប្រឌិត, ជំរុញការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗទាន់សម័យកាល និងផ្តល់ការគាំទ្រដល់ប្រតិបត្តិការផ្នែកព័ត៌មានវិទ្យា សំដៅរក្សានូវភាពប្រកួតប្រជែង និងជៀសវាងពីការវាយប្រហារលើផ្នែកណាមួយនៃអាជីវកម្ម។

**យុទ្ធសាស្ត្រឌីជីថល៖** អ្នកដឹកនាំឌីជីថលដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ និងដឹកនាំអនុវត្តនូវយុទ្ធសាស្ត្រសម្រាប់ការផ្លាស់ប្តូរឌីជីថលរបស់អាជីវកម្ម និងស្ថាប័ន។ យុទ្ធសាស្ត្រឌីជីថលនេះនឹងជួយតម្រង់ទិសអង្គភាពអំពីរបៀបប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានល្អបំផុត ដើម្បីសម្រេចបាននូវគោលដៅអាជីវកម្មរបស់ខ្លួន។

**គោលដៅនៃអាជីវកម្ម៖** អ្នកដឹកនាំឌីជីថលដាក់ចេញនូវគោលដៅអាជីវកម្ម ហើយធ្វើការបែងចែកទំនួលខុសត្រូវការងារតាមផ្នែកនីមួយៗ រួមទាំងកំណត់បច្ចេកវិទ្យាសំខាន់ៗដែលត្រូវប្រើ ដើម្បីជួយអាជីវកម្មសម្រេចគោលដៅ ឆ្លើយតបនឹងតម្រូវការរបស់អតិថិជន និងការវិវត្តនៃនិន្នាការសង្គម សេដ្ឋកិច្ច។

**បង្កើតវប្បធម៌ឌីជីថល៖** អាជីវកម្មក្នុងពេលបច្ចុប្បន្នត្រូវការឧបករណ៍ឌីជីថលខុសៗគ្នា ដើម្បីកែលម្អការងារ និងសម្រួលដល់ដំណើរការនៃអាជីវកម្ម។ អ្នកដឹកនាំឌីជីថល អាចជួយបង្កើតវប្បធម៌ឌីជីថលនៅក្នុងស្ថាប័ន ដោយធ្វើការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាឌីជីថល ដែលសមស្របនឹងតម្រូវការជាក់ស្តែងរបស់អាជីវកម្ម បានចំពេលវេលា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

អ្នកដឹកនាំឌីជីថលមើលឃើញសក្តានុពលនៃបច្ចេកវិទ្យាឌីជីថល និងមានចក្ខុវិស័យក្នុងការចាប់យកសក្តានុពលនោះ ដែលជំរុញឱ្យមានការផ្លាស់ប្តូរនៅក្នុងស្ថាប័ន ឆ្លើយតបនឹងការរីកចម្រើននៃបច្ចេកវិទ្យា។

ខាងក្រោមនេះគឺជាអត្ថប្រយោជន៍នៃភាពជាអ្នកដឹកនាំឌីជីថលសម្រាប់ស្ថាប័ន និងអាជីវកម្ម៖

**បង្កើនផលិតភាព៖** ភាពជាអ្នកដឹកនាំឌីជីថលអាចជួយបង្កើនផលិតភាពក្នុងស្ថាប័ន ចំណេញពេលវេលា និងផ្តល់ភាពងាយស្រួលក្នុងការសម្របខ្លួនដល់បុគ្គលិក។ ឧបករណ៍ឌីជីថលអាចឱ្យអ្នករៀបចំឡើងនូវ Simulation ក្នុងទម្រង់ឌីជីថល ដែលមានសភាពដូចនឹងការងារ, សៀវភៅអេឡិចត្រូនិក (E-Book) ជាដើម សម្រាប់បុគ្គលិកក្នុងការទទួលបាននូវព័ត៌មាន ក៏ដូចជាគោលការណ៍ណែនាំស្តីពីការងារ និងការតាមដានវឌ្ឍនភាពការងាររបស់បុគ្គលិក។ ការប្រើប្រាស់ និងការសម្របខ្លួនជាមួយបច្ចេកវិទ្យាឌីជីថលបានផ្តល់នូវភាពងាយស្រួលក្នុងការបំពេញការងារ ដែលធានាបាននូវផលិតភាពការងារខ្ពស់, ជួយកែលម្អទំនាក់ទំនង និងពង្រឹងនូវកិច្ចសហការក្នុងស្ថាប័ន។

**បង្កើនការចូលរួម និងភាពពេញចិត្តរបស់អតិថិជន៖** ភាពជាអ្នកដឹកនាំឌីជីថលគឺមានសារៈសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវការចូលរួម និងភាពពេញចិត្តរបស់អតិថិជន។ អ្នកដឹកនាំឌីជីថលទទួលយកបច្ចេកវិទ្យាឌីជីថលដើម្បីសម្រួល កែលម្អរបៀបក្នុងការបំពេញការងារ ការផ្តល់សេវាកម្មជូនអតិថិជន និងដៃគូពាក់ព័ន្ធឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនេះ ការប្រើប្រាស់ បច្ចេកវិទ្យាអាចជួយកែលម្អសកម្មភាពការងារនៅក្នុងស្ថាប័ន ឱ្យកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស។ ជាឧទាហរណ៍ បច្ចេកវិទ្យាក៏ដូចជាថ្នាលឌីជីថលមួយចំនួនដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើនការចូលរួម និងភាពពេញចិត្តរបស់អតិថិជន មានដូចជា ប្រព័ន្ធគ្រប់គ្រងទំនាក់ទំនងអតិថិជន **(CRM)**, ប្រព័ន្ធគ្រប់គ្រងបណ្តាញសង្គម, បច្ចេកវិទ្យាក្លោដ, បច្ចេកវិទ្យា **Chatbots** និងការប្រមូលទិន្នន័យ **(Data Collection)** ជាដើម។

**បង្កើនប្រាក់ចំណូល៖** ភាពជាអ្នកដឹកនាំឌីជីថលអាចជួយឱ្យស្ថាប័ន ឬអាជីវកម្មបង្កើនប្រាក់ចំណូល។ អ្នកដឹកនាំឌីជីថលគឺជាអ្នកដែលយល់ពីរបៀបប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើតតម្លៃសម្រាប់ក្រុមហ៊ុនរបស់ពួកគេ។ ពួកគេអាចកំណត់ឱកាសអាជីវកម្មថ្មីៗ និងជំរុញអនុវត្តដំណោះស្រាយបែបឌីជីថល។ ការធ្វើឌីជីថលូបនីយកម្មនៃវំហូរការងារ ការធ្វើផែនការស្តីពីការប្រើប្រាស់ធនធាន ការធ្វើទំនើបកម្មឧបករណ៍ប្រើប្រាស់ និងឧបករណ៍ជាជំនួយ បានជំរុញដល់ប្រសិទ្ធភាពនៃដំណើរការអាជីវកម្ម និងធានាបាននូវបទពិសោធន៍ល្អជូនអតិថិជន។

**បង្កើនអត្រានៃការរក្សាបុគ្គលិក៖** ការផ្លាស់ប្តូរបុគ្គលិកគឺជាបញ្ហាចម្បងសម្រាប់ស្ថាប័ន ហើយការស្វែងរកបុគ្គលិកថ្មី ត្រូវបានចាត់ទុកថាជាដំណើរការមួយដែលចំណាយពេលវេលា, ខាតបង់ចំណូល និងចំណាយថវិកាច្រើន។ នៅក្នុងយុគសម័យឌីជីថល វាកាន់តែមានសារៈសំខាន់សម្រាប់ក្រុមហ៊ុន និងអាជីវកម្ម ដែលមានអ្នកដឹកនាំឌីជីថល អាចប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការទំនាក់ទំនងផ្ទៃក្នុងកន្លែងការងារ, ជួយបង្កើនបទពិសោធន៍ល្អក្នុងការបំពេញការងារ, ជួយដល់ការអភិវឌ្ឍវិជ្ជាជីវៈ និង

ធ្វើឱ្យបុគ្គលិកមានអារម្មណ៍ថាពួកគេជាផ្នែកសំខាន់នៃក្រុមហ៊ុន ដែលទាំងនេះនឹងជួយដល់ការគ្រប់គ្រងធនធានមនុស្សរបស់ស្ថាប័ន និងអាជីវកម្ម។

## II. ភាពជាអ្នកដឹកនាំឌីជីថលនៅកម្ពុជា

សម្រាប់កម្ពុជា ភាពជាអ្នកដឹកនាំឌីជីថលនៅមានកម្រិតនៅឡើយ បើទោះជាគេសង្កេតឃើញនូវកំណើននៃចំនួនអ្នកដឹកនាំឌីជីថល ដែលបានធ្វើការចាប់យក និងប្រើប្រាស់បច្ចេកវិទ្យា ព្រមទាំងថ្នាលឌីជីថលសំខាន់ៗ ជាជំនួយសម្រាប់ដំណើរការការងារ និងអាជីវកម្មរបស់ពួកគេ។ ខណៈដែលការរីកចម្រើននៃការប្រើប្រាស់បច្ចេកវិទ្យាកំពុងមានសន្ទុះគួរឱ្យកត់សម្គាល់នៅកម្ពុជា ជាពិសេសក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងវិស័យសេវាសំខាន់ៗផ្សេងៗទៀត អ្នកដឹកនាំពិតជាមានភាពចាំបាច់ក្នុងការចាប់យកឱកាសនេះ ដើម្បីទាញយកនូវអត្ថប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យា នៅក្នុងការគ្រប់គ្រង និងដំណើរការអាជីវកម្ម។

### ១. បច្ចេកវិទ្យាដែលមានសក្តានុពលសម្រាប់អ្នកដឹកនាំឌីជីថលនៅកម្ពុជា

នៅក្នុងយុគសម័យឌីជីថលនេះ ដើម្បីអាចដឹកនាំអាជីវកម្មឱ្យទទួលបានជោគជ័យ ស្របតាមការវិវត្តឥតឈប់ឈរនៃឌីជីថលូបនីយកម្ម អ្នកដឹកនាំឌីជីថលត្រូវស្វែងយល់ពីបច្ចេកវិទ្យា ដែលឆ្លើយតបនឹងតម្រូវការជាក់ស្តែងក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្ម។ សម្រាប់កម្ពុជា មានបច្ចេកវិទ្យាឌីជីថលសំខាន់ៗមួយចំនួនដែលមានសក្តានុពលសម្រាប់អ្នកដឹកនាំឌីជីថល រួមមាន៖

**ការធ្វើទីផ្សារតាមបែបឌីជីថល (Digital Marketing)៖** នាពេលបច្ចុប្បន្ន ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម បានផ្លាស់ប្តូរការធ្វើទំនាក់ទំនងរវាងអាជីវកម្មជាមួយនឹងអតិថិជន និងកែប្រែយុទ្ធសាស្ត្រក្នុងការធ្វើទីផ្សាររបស់អាជីវកម្ម។ ការណ៍នេះ ទាមទារឱ្យអ្នកដឹកនាំឌីជីថលនៅកម្ពុជាគួរយកចិត្តទុកដាក់លើការធ្វើទីផ្សារតាមបែបឌីជីថល ដែលបានក្លាយជាតម្រូវការមូលដ្ឋានសម្រាប់ការធ្វើអាជីវកម្ម។ អ្នកដឹកនាំឌីជីថល អាចទាញយកផលប្រយោជន៍ពីការធ្វើទីផ្សារបែបឌីជីថលតាមរយៈការផ្សព្វផ្សាយផលិតផល និងសេវាកម្មនៅលើបណ្តាញសង្គម ដូចជា Facebook, Instagram, YouTube និងអ៊ីម៉ែល ដើម្បីបង្កើនការជ្រួតជ្រាបរបស់អតិថិជន ឈានទៅបង្កើនការលក់ផលិតផលនិងសេវាកម្ម។ ការធ្វើទីផ្សារបែបឌីជីថល ក៏អនុញ្ញាតឱ្យអ្នកដឹកនាំឌីជីថលអាចផ្សារភ្ជាប់អាជីវកម្មជាមួយអតិថិជនដោយផ្ទាល់ បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង រាល់ពេលពួកគេប្រើប្រាស់អ៊ីនធឺណិតនិងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ក្រៅពីការប្រាស្រ័យទាក់ទងជាមួយអតិថិជន បច្ចេកវិទ្យាឌីជីថលនេះបានអនុញ្ញាតឱ្យអ្នកដឹកនាំឌីជីថលអាចតាមដានពីប្រសិទ្ធភាពនៃការផ្តល់សេវា តាមរយៈការឆ្លងឆ្លើយការផ្តល់ជាមតិយោបល់ ជាសារ និងការវាយតម្លៃនៅលើគេហទំព័រ និងបណ្តាញសង្គមរបស់អាជីវកម្មជាដើម។ អ្នកដឹកនាំឌីជីថលអាចប្រមូលយកមតិយោបល់ទាំងអស់នោះ យកមកកែលម្អផលិតផលសេវាកម្ម និងយុទ្ធសាស្ត្រអាជីវកម្មបានផងដែរ។



**ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce)៖** ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំង ដោយយោងតាមគេហទំព័រ Statista បានបង្ហាញថាប្រាក់ចំណូលពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានគេព្យាករណ៍ថានឹងកើនដល់ប្រមាណ **១០១៥ លានដុល្លារអាម៉េរិក** នៅក្នុងឆ្នាំ២០២២។ ដូច្នេះ អ្នកដឹកនាំឌីជីថលនៅកម្ពុជាអាចចាប់យកសក្តានុពលពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលអាចឱ្យអាជីវកម្មរបស់គេវាយលុកទាំងទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។ អតិថិជនអាចសាកសួរអំពីផលិតផល ឬសេវាកម្ម និងធ្វើការបញ្ជាទិញបានគ្រប់ពេលវេលា គ្រប់ទីកន្លែង ពីទីតាំងណាមួយ ដែលអនុញ្ញាតឱ្យអ្នកដឹកនាំឌីជីថលអាចចែកចាយផលិតផល និងសេវាកម្មទៅកាន់អតិថិជនបានគ្រប់តំបន់ដែលមានប្រើប្រាស់បណ្តាញអ៊ីនធឺណិត និងអាចជួបដៃគូអាជីវកម្មដែលមានសក្តានុពលនៅទូទាំងពិភពលោកបានផងដែរ។



**ទិន្នន័យធំ និងការវិភាគ (Big Data and Analytics)៖** ការកើនឡើងនូវដំណោះស្រាយទិន្នន័យធំ ដូចជា **SAS, Kissmetrics, Google Analytics, IBM Cognos Analytics និង Qualtrics** បានធ្វើឱ្យការទាញយកផលប្រយោជន៍ពីទិន្នន័យធំលែងជាបញ្ហាចម្បងសម្រាប់អ្នកដឹកនាំឌីជីថលនៅកម្ពុជាទៀតហើយ។ អ្នកដឹកនាំឌីជីថល អាចប្រមូលទិន្នន័យពីប្រភពផ្សេងៗគ្នា ហើយធ្វើការវិភាគដើម្បីឱ្យពួកគេអាចស្វែងរកឫសគល់នៃបញ្ហា, មើលឃើញកាន់តែច្បាស់ពីឥរិយាបថនៃការចំណាយរបស់អ្នកប្រើប្រាស់ ជាពិសេសអាចកាត់បន្ថយហានិភ័យដែលអាជីវកម្មនឹងប្រឈមផងដែរ។ ការស្វែងយល់ឱ្យកាន់តែច្បាស់ពីតម្រូវការរបស់អតិថិជន អាចឱ្យអ្នកដឹកនាំឌីជីថលរៀបចំយុទ្ធសាស្ត្រអាជីវកម្ម, ការធ្វើបច្ចុប្បន្នភាពផលិតផល ឬសេវាកម្មដែលមានស្រាប់ និង/ឬរៀបចំផែនការផលិតកម្ម ថ្មី ដើម្បីបំពេញតម្រូវការរបស់អតិថិជន ដែលនឹងជួយឱ្យអាជីវកម្មដំណើរការបានយ៉ាងរលូន និងទទួលបានចំណូលខ្ពស់។ អ្នកដឹកនាំឌីជីថល ក៏អាចយកទិន្នន័យដែលមាន មកវិភាគអំពីកម្រិតភាពពេញចិត្តរបស់អតិថិជន និងមតិកែលម្អ មកលើផលិតផល ឬសេវាកម្ម ដើម្បីអោយអាជីវកម្មអាចកែប្រែចំណុចខ្វះខាតនោះ។



**ប្រព័ន្ធកុំព្យូទ័រក្លោដ (Cloud Computing)៖** ការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រក្លោដនៅកម្ពុជា មានការកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ប្រព័ន្ធកុំព្យូទ័រក្លោដជាបច្ចេកវិទ្យាឌីជីថលដែលមានសក្តានុពលសម្រាប់អ្នកដឹកនាំឌីជីថល ដោយពួកគេអាចចូលប្រើប្រាស់ទិន្នន័យបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងដែលមានអ៊ីនធឺណិត។ បន្ថែមពីនេះទៀត ប្រព័ន្ធកុំព្យូទ័រក្លោដផ្ទុកទិន្នន័យនៅលើអ៊ីនធឺណិតជាជាងផ្ទុកក្នុងកុំព្យូទ័រ ដែលធានាបានថាទិន្នន័យអាជីវកម្ម ក៏ដូចជាព័ត៌មានអតិថិជនត្រូវបានរក្សាទុកនៅកន្លែងមានសុវត្ថិភាព ដូច្នេះ អ្នកដឹកនាំឌីជីថល មិចបាច់បារម្ភពីការបាត់បង់ឯកសារសំខាន់ៗ ដោយសារការខូចខាតឧបករណ៍នានា។ ការការពារទិន្នន័យអតិថិជនបានយ៉ាងល្អនេះ ជាផ្នែកមួយជួយឱ្យអាជីវកម្មទទួលបាននូវទំនុកចិត្តពីអតិថិជន និងមានប្រៀបជាងដៃគូប្រកួតប្រជែង។ ប្រព័ន្ធកុំព្យូទ័រក្លោដក៏បានជួយកាត់បន្ថយចំណាយរបស់អាជីវកម្ម ដោយអនុញ្ញាតឱ្យមានការចែករំលែកទិន្នន័យជាមួយកុំព្យូទ័រ និងឧបករណ៍ផ្សេងទៀតតាមតម្រូវការ។



**» សន្តិសុខសាយប័រ** (Cyber Security)៖ យើងសង្កេតឃើញថា ការចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅកម្ពុជាសម្រាប់ជាជំនួយដល់អាជីវកម្មមានការកើនឡើងគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល ការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិតបានកើនឡើងជាលំដាប់ដែលធ្វើឱ្យមានការខាតបង់ជាច្រើន ដោយយោងតាមគេហទំព័រ Cybersecurity Ventures ការខូចខាតពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតត្រូវបានគេរំពឹងថានឹងកើនឡើងប្រមាណ ១៥% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ ដែលឈានដល់ប្រមាណ **១០,៥ ទ្រីលានដុល្លារ** នៅឆ្នាំ ២០២៥ ខាងមុខ។ ដូច្នេះ អ្នកដឹកនាំឌីជីថលត្រូវប្រើប្រាស់បច្ចេកវិទ្យាការពារ ឬមានការការពារពីអ្នកជំនាញផ្នែកសន្តិសុខសាយប័រ ដើម្បីទប់ទល់នឹងការគំរាមកំហែងពីការវាយប្រហារតាមអ៊ីនធឺណិត។



## ២. កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថលនៅកម្ពុជា

បច្ចុប្បន្ននេះ ការសម្របខ្លួន និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងចំណោមអ្នកដឹកនាំ ទាំងវិស័យរដ្ឋ, វិស័យឯកជន និងអង្គការ សមាគមនានា នៅក្នុងប្រទេសកម្ពុជា កំពុងមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធ បាននិងកំពុងបន្តជំរុញឌីជីថលូបនីយកម្មនៅក្នុងគ្រប់វិស័យសេដ្ឋកិច្ច សង្គម, គ្រប់ផ្នែក និងគ្រប់កម្រិត ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ជាមួយគ្នានេះ ភាគីពាក់ព័ន្ធបានខិតខំធ្វើការបញ្ជ្រាបការយល់ដឹង រួមទាំងការបណ្តុះបណ្តាលចំណេះ និងជំនាញឌីជីថល ដល់តួអង្គ និងប្រតិបត្តិករ ដែលមានភាពចាំបាច់សម្រាប់ការបណ្តុះស្មារតីនៃភាពជាអ្នកដឹកនាំឌីជីថលនៅកម្ពុជា។ ខាងក្រោមនេះជាកិច្ចខិតខំប្រឹងប្រែងសំខាន់ៗរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថលនៅកម្ពុជា៖

## ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីភាពជាអ្នកដឹកនាំឌីជីថល តាមរយៈដាក់ចេញនូវក្របខណ្ឌគោលនយោបាយ, គោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាអាទិភាពនានា សំដៅជំរុញការកសាងសេដ្ឋកិច្ច សង្គមឌីជីថលនៅកម្ពុជា។ ជាមួយគ្នានេះ យន្តការប្រទាក់ក្រឡាគ្នាដែលមានភាពចាំបាច់នានាត្រូវបានដាក់ចេញជាបន្តបន្ទាប់ ដើម្បីកសាងបាននូវមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការសម្រេចបានចក្ខុវិស័យវែងឆ្ងាយនៃការអភិវឌ្ឍជាតិ ក្នុងនោះការអភិវឌ្ឍធនធានមនុស្សឱ្យមានភាពជាអ្នកដឹកនាំឌីជីថល គឺជាកិច្ចការដ៏សំខាន់មួយ ដែលទាមទារឱ្យអ្នកដឹកនាំត្រូវបង្កើនការទទួលយក និងការសម្របខ្លួនទៅនឹងការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា ដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មី ផ្អែកលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថល សម្រាប់ការធ្វើអភិបាលកិច្ច ការប្រាស្រ័យទាក់ទង ការសម្រេចចិត្ត និងការដោះស្រាយបញ្ហានានា។

នៅក្នុងឯកសារ **«ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥»** រាជរដ្ឋាភិបាលបានកំណត់គោលដៅមួយក្នុងចំណោមគោលដៅចំបងនានា គឺ**ការកសាងពលរដ្ឋឌីជីថល** ដែលផ្ដោតលើការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថល, ការអភិវឌ្ឍ និងការប្រមូលធនធានមនុស្សដែលមានទេពកោសល្យឌីជីថល និងការប្រែក្លាយទៅជាពលរដ្ឋឌីជីថល ដើម្បីបង្កើតជាចលករនៃបរិវត្តកម្មឌីជីថល។ នៅក្នុងវិស័យសាធារណៈ រាជរដ្ឋាភិបាលបានកំណត់នូវវិធានការសំខាន់ៗ ដើម្បីអភិវឌ្ឍន៍សមត្ថភាពនៃអ្នកដឹកនាំឌីជីថល ដូចជា៖

- ការរៀបចំក្របខណ្ឌរួមស្ដីពីការលើកកម្ពស់អក្ខរកម្មឌីជីថល ក្នុងចំណោមអ្នកដឹកនាំ និងមន្ត្រីនៅតាមក្រសួង ស្ថាប័នរដ្ឋ,
- ការរៀបចំក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅតាមក្រសួងស្ថាប័នរដ្ឋ,
- ការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការផ្លាស់ប្ដូរជាដំណាក់កាលលើនីតិវិធីរដ្ឋបាល និងរបៀបនៃការគ្រប់គ្រង និងការចាត់ចែងការងារ នៅតាមក្រសួង ស្ថាប័នរដ្ឋ,
- ការរៀបចំផែនការរយៈពេលខ្លី និងមធ្យម សម្រាប់ការជំរុញការចាប់យក និងការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និងចាត់ចែងការងារ ព្រមទាំងការជំរុញ និងលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញឌីជីថល និងភាពជាអ្នកដឹកនាំឌីជីថល នៅក្នុងវិស័យរដ្ឋ និងវិស័យឯកជន,
- ការបង្កើនការផ្ទេរធនធាន និងការកៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកា ក៏ដូចជាកិច្ចសហប្រតិបត្តិការនានា ពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន សម្រាប់ការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅថ្នាក់ក្រោមជាតិ។

## គោលនយោបាយរដ្ឋាភិបាលឌីជីថល ឆ្នាំ២០២២-២០៣៥

ការកសាងមូលធនមនុស្សឌីជីថល ត្រូវបានកំណត់ជាអាទិភាពមួយនៅក្នុង **«គោលនយោបាយរដ្ឋាភិបាលឌីជីថល ឆ្នាំ២០២២-២០៣៥»** ដែលផ្តោតជាសំខាន់លើការកសាងសមត្ថភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលសម្រាប់បម្រើដល់ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលឌីជីថល ឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ សកម្មភាពយុទ្ធសាស្ត្រជាច្រើនត្រូវបានកំណត់ មានជាអាទិ៍៖ ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំឌីជីថល, ការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល, ការរៀបចំក្របខណ្ឌវាស់វែងកម្រិតសមត្ថភាពឌីជីថល, ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធឌីជីថល, ការរៀបចំថ្នាលអប់រំ និងបណ្តុះបណ្តាលជាតិ, និងការរៀបចំកម្មវិធីតម្រង់ទិសនានា។

## អាហារូបករណ៍ទេពកោសល្យឌីជីថលតេជោ (Techo Digital Talent Scholarship)

ក្រោមការគិតគូរយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើការកសាងធនធានមនុស្សឆ្នើម និងអនាគតយុវជនក្នុងយុគសម័យឌីជីថល រាជរដ្ឋាភិបាលបានបន្តផ្តល់នូវ **«អាហារូបករណ៍ទេពកោសល្យឌីជីថលតេជោ - Techo Digital Talent Scholarship»** ដើម្បីផ្តល់ឱកាសដល់ធនធានមនុស្សដែលមានសមត្ថភាព និងទេពកោសល្យ សំដៅបង្កើនអ្នកជំនាញបច្ចេកវិទ្យាឌីជីថលក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមឌីជីថល រដ្ឋាភិបាលឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម ៤.០។ អាហារូបករណ៍នេះនឹងផ្តល់ឱកាសដល់និស្សិតទទួលបាននូវចំណេះដឹង ចំណេះធ្វើ និងជំនាញយ៉ាងពិតប្រាកដ ក្លាយខ្លួនជាអ្នកដឹកនាំលើវិស័យបច្ចេកវិទ្យាឌីជីថលនាពេលអនាគត។

## មជ្ឈមណ្ឌលកម្ពុជា ៤.0

**មជ្ឈមណ្ឌលកម្ពុជា ៤.0** សហការជាមួយ**សហភាពសហព័ន្ធយុវជនកម្ពុជា** និងភាគីពាក់ព័ន្ធ បាននិងកំពុងបន្តរៀបចំ **«វគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថល»** ដែលផ្តោតលើប្រធានបទសំខាន់ៗសម្រាប់ការសិក្សា ការបំពេញការងារ ការប្រកបអាជីវកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃ។ កម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនេះបានចូលរួមអភិវឌ្ឍន៍ចំណេះ និងជំនាញឌីជីថល សម្រាប់បុគ្គលិកឯកជន អ្នកគ្រប់គ្រងម្ចាស់អាជីវកម្ម ក៏ដូចជាមន្ត្រីរាជការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅឆ្លើយតបនឹងតម្រូវការនៃការប្រើប្រាស់បច្ចេកវិទ្យា។

ទន្ទឹមនេះ **មជ្ឈមណ្ឌលកម្ពុជា ៤.0** បាននឹងកំពុងបន្តផ្សព្វផ្សាយ**វីដេអូអក្ខរកម្មតាមប្រព័ន្ធអនឡាញ (E-learning)** រួមជាមួយនិងការរៀបចំកម្មវិធី **"ជជែកពីកម្ពុជា ៤.0"** ដើម្បីចូលរួមបញ្ជ្រាបការយល់ដឹង និងពង្រឹងសមត្ថភាពប្រជាពលរដ្ឋ និងយុវជន ឈានទៅការបង្កើនផលិតភាព ប្រសិទ្ធភាពការងារ និងអាជីវកម្ម។ លើសពីនេះទៀត **មជ្ឈមណ្ឌលកម្ពុជា ៤.0** ក៏បានរៀបចំចងក្រង**ឯកសារសិក្សាស្រាវជ្រាវ**

**អំពីសេដ្ឋកិច្ច សង្គមឌីជីថល** ដោយផ្តោតលើប្រធានបទសំខាន់ៗ និងបានផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញជាប្រចាំ ដែលផ្តល់ភាពងាយស្រួលដល់សាធារណជនក្នុងការស្វែងយល់ និងចែករំលែកបន្តបានគ្រប់ពេល ព្រមទាំងអាចរក្សាទុកមើលបានដោយឥតគិតថ្លៃ ហើយក៏មានការតម្កល់សៀវភៅកម្រងអត្ថបទសិក្សាទាំងនេះនៅតាមបណ្ណាល័យនៃក្រសួង ស្ថាប័ន និងសាកលវិទ្យាល័យផងដែរ។

**SmartEdu USDP**

ដោយមានការគាំទ្រពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងអប់រំ យុវជន និងកីឡា ក្រុមហ៊ុន **Smart Axiata** បានរៀបចំនូវកម្មវិធី **SmartEdu USDP** ដើម្បីផ្តល់ឱកាសឱ្យនិស្សិតទទួលបានការសិក្សាអំពីជំនាញ និងភាពជាអ្នកដឹកនាំឌីជីថល ក៏ដូចជាប្រធានបទសំខាន់ៗក្នុងវិស័យអាជីវកម្ម តាមរយៈសិក្ខាសាលា ការអនុវត្តការងារជាក្រុម និងការអនុវត្តដោះស្រាយបញ្ហាអាជីវកម្ម ។

## III. សន្និដ្ឋាន

ជារួម ភាពជាអ្នកដឹកនាំឌីជីថលពិតជាសមាសធាតុដែលមិនអាចខ្វះបាន ក្នុងការធានាការដឹកនាំប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល នៅក្នុងយុគសម័យឌីជីថលនេះ។ ជាមួយចក្ខុវិស័យច្បាស់លាស់, ភាពច្នៃប្រឌិត និងបណ្តាញទំនាក់ទំនងល្អ អ្នកដឹកនាំឌីជីថលអាចជួយបង្កើនផលិតភាពក្នុងស្ថាប័ន, បង្កើនភាពពេញចិត្តរបស់អតិថិជន, បង្កើនចំណូលអាជីវកម្ម ព្រមទាំងបង្កើនលទ្ធភាពក្នុងការរក្សាបុគ្គលិក តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាចំគោលដៅ, ស្របតាមតម្រូវការជាក់ស្តែងរបស់អាជីវកម្ម និងស្ថាប័ន, បានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ដោយឡែក នៅកម្ពុជា ភាពជាអ្នកដឹកនាំឌីជីថលបាននឹងកំពុងមានសន្ទុះរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតលើបច្ចេកវិទ្យាឌីជីថលដែលមានសក្តានុពល ដូចជា ការធ្វើទីផ្សារតាមបែបឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ទិន្នន័យធំ និងការវិភាគ, ប្រព័ន្ធកុំព្យូទ័រក្លោដ និងសន្តិសុខសាយប័រ ជាដើម។

ទន្ទឹមនេះ ដើម្បីជំរុញការកសាងសេដ្ឋកិច្ច សង្គមឌីជីថលនៅកម្ពុជា រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធបាននិងកំពុងជំរុញ និងលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថល ទាំងនៅក្នុងវិស័យរដ្ឋ, វិស័យឯកជន និងអង្គការ សមាគមនានា តាមរយៈការដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងវិធានការសំខាន់ៗ រួមជាមួយយន្តការអនុវត្តដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា និងដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ពិសេសការបណ្តុះបណ្តាល និងតម្រង់ទិសភាពជាអ្នកដឹកនាំឌីជីថល និងការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល។ កិច្ចការទាំងនេះនឹងជំរុញឱ្យអ្នកដឹកនាំគ្រប់ផ្នែក គ្រប់វិស័យ និងគ្រប់កម្រិត បង្កើនការទទួលយក និងការសម្របខ្លួនទៅនឹងការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា ដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មីផ្អែកលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថល សម្រាប់ការធ្វើអភិបាលកិច្ច ការប្រាស្រ័យទាក់ទង ការសម្រេចចិត្ត និងការដោះស្រាយបញ្ហានានា។

## ឯកសារយោង


- What is Digital Leadership, ចេញផ្សាយថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២២, ចូលអានថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២, https://gdsgroup.com/insights/article/what-is-digital-leadership/#:~:text=It%20Enables%20Employee%20Productivity%20%E2%80%93%20The,most%20out%20of%20these%20tools.
- Digital transformation is driving economic change, ចេញផ្សាយថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២២, ចូលអានថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.khmertimeskh.com/501014039/digital-transformation-is-driving-economic-change/
- What is Digital Leadership? Why is it important?, ចេញផ្សាយថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០២២, ចូលអានថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.edureka.co/blog/digital-leadership
- How Digital Leadership Inspires Staff Productivity ?, ចេញផ្សាយថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៨, ចូលអានថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.entrepreneur.com/en-ae/technology/how-digital-leadership-inspires-staff-productivity/321466#:~:text=Digital%20leadership%20allows%20you%20to,to%20track%20an%20employee's%20progress
- 5 Ways Technology Supports Improved Employee Retention?, ចេញផ្សាយថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២២, ចូលអានថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២, https://blogs.oracle.com/government-education/post/5-ways-technology-supports-improved-employee-retention
- សេចក្តីជូនដំណឹង ស្តីពី "អាហារូបករណ៍ទេពកោសល្យឌីជីថលតេជោ – Techo Digital Talent Scholarship", ចូលអានថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២, https://mptc.gov.kh/featured-km/27816/
- The SmartEdu University Student Development Program, ចូលអានថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.smartedu.com.kh/index.php/en/
- អ្នកដឹកនាំឌីជីថលវ័យក្មេងឈ្នះឱកាសហាត់ការជាមួយ Axiata Group, ចេញផ្សាយ ខែវិច្ឆិកា ឆ្នាំ ២០២២, ចូលអានថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.smart.com.kh/km/axiata-group-internships-awarded-to-future-digital-leaders-in-smartedu-usdp-program/
- Effective Digital Leadership Is Key To Digital Transformation, ចេញផ្សាយថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០២១, ចូលអានថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.forbes.com/sites/forbesagencycouncil/2021/07/21/effective-digital-leadership-is-key-to-digital-transformation/?sh=4c7b3bec1069
- Digital Leadership: The Challenges, Skills, and Technology, ចេញផ្សាយថ្ងៃទី២០ ខែមករា ឆ្នាំ២០២១, ចូលអានថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២, https://metasfresh.com/en/2021/01/20/digital-leadership-the-challenges-skills-and-technology/
- Big Data Analytics: What it is and why it matters, ចូលអានថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.sas.com/en_us/insights/analytics/big-data-analytics.html#:~:text=Big%20data%20analytics%20helps%20organizations,Reducing%20cost

- *Why CIOs Choose Big Data Analytics implementations for digital transformation?* ចូលអានថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.saviantconsulting.com/blog/big-data-analytics-solutions-digital-transformation.aspx
- *Top 7 Benefits of Big Data and Analytics and Reasons to Consider It For Your Next Career Move,* ចេញផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២, ចូលអានថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.simplilearn.com/benefits-of-big-data-and-analytics-article
- *What is Cloud Computing and Who Uses Cloud Service?* ចេញផ្សាយថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២, ចូលអានថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.simplilearn.com/tutorials/cloud-computing-tutorial/what-is-cloud-computing
- *Leadership in the Cloud Computing Era,* ចេញផ្សាយខែកក្កដា ឆ្នាំ២០១១, ចូលអានថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.spencerstuart.com/research-and-insight/leadership-in-the-cloud-computing-era
- *Opinion: What the Public Should Know About Cybersecurity in Cambodia,* ចេញផ្សាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២, ចូលអានថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២, https://cambodianess.com/article/opinion-what-the-public-should-know-about-cybersecurity-in-cambodia
- *Cybercrime as empire would be the world's third-largest economy,* ចេញផ្សាយថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០២២, ចូលអានថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២, https://10guards.com/en/articles/cybercrime-as-empire-would-be-the-worlds-third-largest-economy/
- *Why Cybersecurity Is Now A Board-Level Leadership Imperative,* ចេញផ្សាយថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២, ចូលអានថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.forbes.com/sites/forbesbusinesscouncil/2022/05/19/why-cybersecurity-is-now-a-board-level-leadership-imperative/?sh=4263af654270
- *10 Clear Reasons Why You Need Digital Marketing,* ចេញផ្សាយថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨, ចូលអានថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.ballantine.com/10-undeniable-reasons-need-digital-marketing/
- *E-Commerce-Cambodia,* ចូលអានថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.statista.com/outlook/dmo/ecommerce/cambodia
- *What Are Leadership Vision Statements?,* ចេញផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១, ចូលអានថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.indeed.com/career-advice/career-development/leadership-vision-statements#:~:text=Leadership%20vision%20is%20the%20ability,addressed%20and%20your%20future%20aspirations.
- *25 Leadership Qualities That Makes You A Good Leader,* ចេញផ្សាយថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ២០២២, ចូលអានថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២, https://blog.vantagecircle.com/leadership-qualities/
- *The Importance of Leadership Networking,* ចេញផ្សាយថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១៨, ចូលអានថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២, https://www.dukematlock.com/leadership-networking/

- *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥, ចេញផ្សាយខែឧសភា ឆ្នាំ ២០២១, ចូលអានថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច_និងសង្គមឌីជីថលកម្ពុជា_ឆ្នាំ២០២១_២០៣៥.pdf (ocm.gov.kh)*
- *គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ២០២២-២០៣៥, ចេញផ្សាយខែមករា ឆ្នាំ ២០២២, ចូលអានថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២, https://trc.gov.kh/wp-content/uploads/policy/Digital-Government-Policy-2022-2035-1.pdf*

---


www.cambodia4point0.org

កម្ពុជា ៤.0 - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center